## ចំណាយបន្ទុកបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិក ឆ្នាំ២០១៥ Wage and Non-wage Expenses 2015

| គម្រោងចំណាយ Projected Expenses | 2015 ថវិ. BL (លានរៀល) Millions Riel | % កំណើន %Change | % ផសស % GDP |
|---|---|---|---|
| ចំណាយចរន្តថវិការដ្ឋ Total Current Expenditure | 9,806,600 | 12.46 | 13.17 |
| បន្ទុកបុគ្គលិក Wage Expense | 4,767,596 | 23.40 | 6.40 |
| មិនមែនបន្ទុកបុគ្គលិក Non-Wage Expense | 5,039,004 | 3.76 | 6.77 |
| -ថវិកាថ្នាក់ជាតិ National Budget | 9,275,161 | 12.17 | 12.46 |
| បន្ទុកបុគ្គលិក Wage Expense | 4,566,407 | 20.71 | 6.13 |
| មិនមែនបន្ទុកបុគ្គលិក Non-Wage Expense | 4,708,754 | 4.97 | 6.33 |
| -ថវិកាថ្នាក់ក្រោមជាតិ Sub-national Budget | 974,335 | 65.30 | 1.31 |
| បន្ទុកបុគ្គលិក Wage Expense | 201,189 | 149.19 | 0.27 |
| មិនមែនបន្ទុកបុគ្គលិក Non-Wage Expense | 773,146 | 51.98 | 1.04 |

## ចំណូល-ចំណាយថ្នាក់ក្រោមជាតិ ឆ្នាំ២០១៥ Sub-national Revenue and Expenditure 2015

| សូចនាករ (%ផសស) Indicators (%GDP) | 2014 ថវ. BL. | 2015 ថវ. BL. |
|---|---|---|
| ចំណូលចរន្ត Current Revenue | 0.84 | 0.89 |
| ចំណាយសរុប Total Expenditure | 1.05 | 1.49 |
| ចំណាយចរន្ត Current Expense | 0.87 | 1.31 |
| ចំណាយមូលធន Capital Expenditure | 0.18 | 0.18 |

## ចំណែកក្រសួងអនុវត្តថវិកាកម្មវិធី ជាភាគរយនៃចំណាយចរន្តថ្នាក់ជាតិ ឆ្នាំ២០១៥ Share of Ministries with Program Budget as % National Current Budget 2015




## សេចក្តីសន្និដ្ឋាន Conclusion

ថវិកាឆ្នាំ២០១៥ ជាថវិកាមានចរិតកែទម្រង់ និងកែលម្អទាំងផ្នែករៀបចំ ទាំងផ្នែកខ្លឹមសារ ដើម្បីបម្រើជាឧបករណ៍ដ៏មានប្រសិទ្ធភាពឆ្លើយតបទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនិងបំណងប្រាថ្នារបស់ប្រជាជន ក្នុងបរិការណ៍ សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ ការវិវឌ្ឍនៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ឱ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា។

Budget 2015 is a budget with in-depth reform characteristics and with the improvement of both preparation process and its contents to serve as an effective tool for responding to the priority policies of the government and to the desire of the people in the context of the regional integration, globalization, as well as the management capacity for economic and social development, in line with the new phase of Cambodia.



ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
Ministry of Economy and Finance
នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា
General Department of Budget, Budget Formulation Department

**2015**

# ថវិកាសង្ខេប Budget in Brief

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ត្រូវបានរៀបចំនៅក្នុងបរិការណ៍ដែលកម្ពុជាបាននិងកំពុងធ្វើដំណើរនៅលើគន្លងនៃលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ព្រមទាំងធានានិងរក្សាបាននូវ សន្តិភាព ស្ថិរភាពនយោបាយ សាមគ្គីភាព និងការបង្រួបបង្រួមជាតិ ដោយផ្អែកលើភាពចាស់ទុំខាងនយោបាយ។ ទន្ទឹមនឹងនេះ សេដ្ឋកិច្ចកម្ពុជាក៏បានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ គឺកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប និងស្ថិតក្នុងដំណើរនៃការផ្លាស់ប្តូរជារចនាសម្ព័ន្ធ។

Law on Financial Management for 2015 has been prepared in the context that Cambodia is moving on the path of democracy and rule of law while peace, political stability, solidarity and unity of the nation have been ensured and preserved based on the political seniority. Furthermore, Cambodian economy is at a new stage of development, transformation process of becoming a lower middle income country.

## ទស្សនវិជ្ជា និងគោលការណ៍នៃការរៀបចំថវិកាឆ្នាំ២០១៥ Philosophy and Principle of 2015 Budget Preparation

១- គោរពឲ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច ដែលបានកំណត់
២- បង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
៣- ប្រឹងប្រែងប្រមូលចំណូលឲ្យអស់លទ្ធភាព និងអស់សក្តានុពល
៤- រៀបចំក្របខណ្ឌចំណាយដោយផ្អែកលើលទ្ធភាពថវិកា÷ ប្រសិទ្ធភាពទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ/បច្ចេកទេស
៥- ផ្សារភ្ជាប់ការដំឡើងប្រាក់បៀវត្ស និងការកែទម្រង់ប្រព័ន្ធបៀវត្ស ទៅនឹងការកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈ ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
៦- បន្តពង្រឹងដោយប្រុងប្រយ័ត្នខ្ពស់ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ

1. Strictly follow pre-specified macroeconomic framework
2. Strengthen the linkage between budget and policy
3. Collect revenues as efficiently and effectively as possible
4. Prepare expenditure framework based on the affordability of budget and improvement in allocation and technical efficiency
5. Link the increase in wage and wage system reform with public administration reform, public finance reform and the fight against corruption.
6. Continue strengthening public debts management

## ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច (២០១៣-២០១៥) Macroeconomic Framework (2013-2015)

| សូចនាករសេដ្ឋកិច្ចសំខាន់ៗ Key economic indicators | 2013 អនុ. Act. | 2014 ប៉ាន់. Est. | 2015 ព្យា. Forecast |
|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ពាន់លានរៀល) Nominal GDP (Billions Riel) | 61,414 | 67,643 | 74,444 |
| កំណើនផសស ពិត (%) Real GDP Growth (%) | 7.4% | 7.0% | 7.0% |
| ផសស សម្រាប់ម្នាក់ (ដុល្លារ) GDP per capita (USD) | 1,043 | 1,130 | 1,225 |
| អត្រាអតិផរណា (មធ្យមប្រចាំឆ្នាំ) Inflation Rate (Year Avg.) | 3.0% | 3.5% | 3.5% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) Exchange Rate (Riel/USD) | 4,025 | 4,050 | 4,050 |
| ឱនភាពគណនីចរន្ត (% ផសស) Current Acc. Deficit (%GDP) | -12.5% | -11.1% | -10.3% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារ) Int. Foreign Reserves (Millions USD) | 3,564 | 4,593 | 5,144 |

## វិភាគទានតាមវិស័យនៅក្នុងកំណើននៃ ផសស
## Sectoral contributions to the growth of GDP

| វិស័យ/អនុវិស័យ Sector/Sub-sector | 2014 ប៉ាន់. Est. | 2015 ព្យ. Forecast |
|---|---|---|
| **កសិកម្ម នេសាទ និងព្រៃឈើ** Agriculture, Fishery & Forestry | **0.6%** | **0.9%** |
| *ក្នុងនោះ ដំណាំ Crops* | *0.3%* | *0.4%* |
| **ឧស្សាហកម្ម** Industry | **2.9%** | **2.8%** |
| *ក្នុងនោះ ឧស្សាហកម្មកាត់ដេរ Garment Industry* | *1.2%* | *1.5%* |
| *សំណង់ Construction* | *1.1%* | *0.8%* |
| **សេវាកម្ម** Services | **2.9%** | **2.8%** |
| *ក្នុងនោះ ពាណិជ្ជកម្ម Trade* | *0.5%* | *0.5%* |
| *សណ្ឋាគារ និងភោជនីយដ្ឋាន Hotels & Restaurants* | *0.4%* | *0.5%* |
| *អចលនទ្រព្យ និងជំនួញ Real Estates & Business* | *0.6%* | *0.5%* |
| **ពន្ធលើផលិតផលដកឧបត្ថម្ភធន** Taxes on Products less Subsidies | **0.6%** | **0.4%** |
| **កំណើន ផសស ថេរ Real GDP Growth** | **7.0%** | **7.0%** |

## ផ្នែកសំខាន់ៗនៃសេដ្ឋកិច្ចជា %ផសស (តាមថ្លៃបច្ចុប្បន្ន)
## Important Shares of Economy as %GDP (at current price)

| វិស័យ/អនុវិស័យ Sector/Sub-sector | 2014 ប៉ាន់. Est. | 2015 ព្យ. Forecast |
|---|---|---|
| **កសិកម្ម** Agriculture | **29.70%** | **29.00%** |
| ដំណាំ Crops | 17.50% | 17.09% |
| ជលផល Fisheries | 7.05% | 6.94% |
| **ឧស្សាហកម្ម** Industry | **25.31%** | **26.18%** |
| វាយនភ័ណ្ឌ,សំលៀកបំពាក់ និងស្បែកជើង Textile, Wearing Apparel & Footwear | 10.09% | 10.45% |
| សំណង់ Construction | 8.28% | 8.76% |
| **សេវាកម្ម** Services | **39.21%** | **39.43%** |
| ពាណិជ្ជកម្ម Trade | 8.96% | 8.90% |
| សណ្ឋាគារនិងភោជនីយដ្ឋាន Hotels & Restaurants | 5.14% | 5.36% |
| ហិរញ្ញវត្ថុ Finance | 1.72% | 1.75% |
| អចលនទ្រព្យ និងជំនួញ Real Estate & Business | 6.16% | 6.26% |

## ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៥
## Public Finance Framework 2015








ចំណុចលេចធ្លោជាងគេនៃថវិកាឆ្នាំ២០១៥ **គឺការផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើការតម្លើងបៀវត្សមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ,** ទន្ទឹមនឹងការបង្កើនចំណាយលើសកម្មភាពអាទិភាព និងការកែទម្រង់សំខាន់ៗ ក្នុងវិស័យរដ្ឋបាលទូទៅ វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ, វិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច។ ជាក់ស្តែង ថវិកាឆ្នាំ២០១៥បានបង្កើនចំណាយបន្ទុកបុគ្គលិកពីកម្រិតគោល**៤០%**នៃចំណាយចរន្តសរុប ឱ្យឡើងរហូតដល់ប្រមាណ**៤៨,៦២%** នៃចំណាយចរន្តសរុប ដែលស្មើប្រមាណ**៦,៤០%** នៃផសសក្នុងគោលដៅលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈជូនប្រជាពលរដ្ឋទូទៅ ទន្ទឹមនឹងការបន្តសន្សំសំចៃ និងការធ្វើវិចារណកម្មចំណាយមិនមែនបន្ទុកបុគ្គលិក និងការធានាបានជាសារវន្តនូវចំណាយវិនិយោគ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចដូចដែលបានគ្រោងទុក។

The outstanding point of the budget 2015 is to focus particularly on the increase in salary of civil servants and the armed forces of all kinds, while also increasing the spending on priority activities and key reforms in the general administration sector, defense-security and public order sector, social sector and economic sector. Actual Budget 2015 has increased Wage Expense from a threshold of 40% to about 48.62% of the total current expenditure, which equals approximately 6.40% of GDP for the purpose of promoting the livelihoods of officials and armed forces and to improve the quality and efficiency of public services to ordinary people, along with the continued savings and rationalize non-wage expenses and essentially guarantee the investment costs to sustain economic growth, as pre-specified.

| សូចនាករថវិកា (%ផសស) Budget Indicators (%GDP) | 2014 ថវ. BL. | 2015 ថវ. BL. |
|---|---|---|
| ចំណូលក្នុងប្រទេសថវិការដ្ឋ Total State Domestic Revenue | 15.52% | 15.87% |
| *ចំណូលចរន្តថវិការដ្ឋ Total Current Revenue* | 15.18% | 15.69% |
| ចំណាយសរុបថវិការដ្ឋ Total State Expenditure | 20.90% | 21.09% |
| *ចំណាយចរន្តថវិការដ្ឋ Total current Expense* | 12.87% | 13.17% |
| **អតិរេកចរន្ត Current Surplus** | **2.31%** | **2.52%** |
| **ឱនភាពសរុប Total Deficit** | **-5.39%** | **-5.22%** |




## ចំណូលថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ជា %ផសស
## National Revenue 2015 as %GDP

| សូចនាករ (%ផសស) Indicators (%GDP) | 2014 ថវ. BL. | 2015 ថវ. BL. |
|---|---|---|
| ចំណូលថវិកាថ្នាក់ជាតិសរុប Total National Revenue | 20.16 | 20.33 |
| ចំណូលក្នុងប្រទេសថ្នាក់ជាតិ National Domestic Revenue | 14.68 | 14.98 |
| ចំណូលចរន្តថ្នាក់ជាតិ National Current Revenue | 14.33 | 14.80 |
| ចំណូលមូលធន Total Capital Revenue | 5.83 | 5.54 |
| មូលធនក្នុងប្រទេស Domestic Capital Revenue | 0.34 | 0.18 |
| មូលធនក្រៅប្រទេស Foreign Capital Revenue | 5.49 | 5.36 |

## ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ជា %ផសស
## National Expenditure 2015 as %GDP

| សូចនាករ (%ផសស) Indicators (%GDP) | 2014 ថវ. BL. | 2015 ថវ. BL. |
|---|---|---|
| ចំណាយថវិកាថ្នាក់ជាតិសរុប Total National Expenditure | 20.06 | 20.20 |
| ចំណាយចរន្តថ្នាក់ជាតិ National Current Expenditure | 12.20 | 12.46 |
| ចំណាយមូលធនថ្នាក់ជាតិ National Capital Expenditure | 7.86 | 7.74 |
| វិនិយោគសាធារណៈ: ហិរញ្ញប្បទានក្នុងប្រទេស Domestic Financed Investment | 2.27 | 2.20 |
| វិនិយោគសាធារណៈ: ហិរញ្ញប្បទានក្រៅប្រទេស Foreign Financed Investment | 5.11 | 4.95 |
| ការទូទាត់ប្រាក់ខ្ចី Loan payments | 0.49 | 0.59 |